# សេចក្តីថ្លែងការណ៍រួម

# សកម្មភាពលោក ជា ចាន់ថា មិនមែនជាបទល្មើស

ចេញផ្សាយថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៤

យើងខ្ញុំជា អង្គការសង្គមស៊ីវិល សមាគម សហព័ន្ធ សហជីព ពិតជាមានការខកចិត្តជាខ្លាំងចំពោះសាលាដំបូងខេត្តស្វាយរៀង ដែលបានសម្រេចចោទប្រកាន់ និងបញ្ជូនលោក **ជា ចាន់ថា** ទៅឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៤ ។ លោក ជា ចាន់ថា ជាថ្នាក់ដឹកនាំតំបន់របស់សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ(IDEA) ការងារដែលលោកបានធ្វើក្នុងខេត្តស្វាយរៀងកាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ ជាសកម្មភាពស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលទាក់ទងនឹងបេឡាជាតិសន្តិសុខសង្គម (បសស) ប៉ុន្តែបែរជាលោក **ជា ចាន់ថា** ត្រូវរងការចោទប្រកាន់ពីបទឆបោក យោងតាមមាត្រា ៣៧៧ និង ៣៧៨ និងបទធ្វើសកម្មភាពបង្កើតឱ្យមានការយល់ច្រឡំជាមួយការបំពេញមុខងារសាធារណៈ យោងតាមមាត្រា ៦១០ នៃក្រមព្រហ្មទណ្ឌ ដែលលោកអាចនឹងប្រឈមមុខជាប់ពន្ធនាគាររហូតដល់៣ឆ្នាំ ។

កន្លងមកសមាគមធ្លាប់បានធ្វើជាវេទិកាពន្យល់ស្តីអំពីកិច្ចគាំពារសង្គមនៅថ្នាក់មូលដ្ឋានតាមបណ្តាខេត្តដោយមានការអញ្ជើញមន្ត្រីបេឡាជាតិសន្តិសុខសង្គម (បសស) ដើម្បីចូលរួមជួយពន្យល់ឱ្យកម្មវិធីនេះបានជ្រួតជ្រាបដល់ថ្នាក់មូលដ្ឋាន បងប្អូនអាជីវករ អ្នកលក់ដូរតាមដងផ្លូវ អ្នកធ្វើការតាមផ្ទះ ដើម្បីបានដឹង ហើយទទួលយកកម្មវិធីបេឡាជាតិរបបសន្តិសុខសង្គម ដោយទៅចុះបញ្ជីចូលជាសមាជិកដោយស្ម័គ្រចិត្ត ។ លោក **ជា ចាន់ថា** និងសកម្មជនផ្សេងទៀត បានចុះធ្វើកិច្ចការងារនេះទាំងអស់គ្នា កិច្ចការងារនេះ ស្របទៅតាមទិសដៅរបស់រាជរដ្ឋាភិបាល និងក៏ជាចំណែកមួយក្នុងការការពារបងប្អូនដែលកំពុងប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ បានចូលក្នុងប្រព័ន្ធឆាប់រហ័ស ។

ក្រោយពីលោកបានទទួលនូវចំណេះដឹងពីមន្ត្រីបេឡាជាតិសន្តិសុខសង្គម ដែលខាងសមាគម បានអញ្ជើញមកធ្វើការចែករំលែកនូវអត្ថប្រយោជន៍ក្នុងការទទួលបានការថែទាំសុខភាពស្របទៅតាមអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ២៨០ អ.នក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣ ផ្នែករបបថែទាំសុខភាពដោយស្ម័គ្រចិត្ត ។ លោក **ជា ចាន់ថា** បានចូលរួមផ្សព្វផ្សាយបន្តអំពីសារៈប្រយោជន៍នៃការក្លាយជាសមាជិកបេឡាជាតិសន្តិសុខសង្គម ដល់បងប្អូន ដែលប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ។

យើងខ្ញុំជា អង្គការសង្គមស៊ីវិល សមាគម សហព័ន្ធ សហជីព ស្នើឱ្យស្ថាប័នតុលាការ មេត្តាធ្វើការទម្លាក់ចោលនូវការចោទប្រកាន់លោក **ជា ចាន់ថា** ដែលការផ្សព្វផ្សាយពីបេឡាជាតិសន្តិសុខសង្គមនេះ មិនមែនសកម្មភាពណាមួយបំផ្លិចបំផ្លាញប្រយោជន៍ជាតិឡើយ ផ្ទុយទៅវិញបើមានការដោះលែងលោក **ជា ចាន់ថា** នឹងអាចធ្វើឱ្យលោកបន្តមុខរបរក្នុងការលើកស្ទួយសេដ្ឋកិច្ចជាតិ ដោះស្រាយបញ្ហាជីវភាពគ្រួសារ ដែលជួយដល់សង្គមជាតិផងដែរ ។

ជាពិសេសសកម្មភាពរបស់លោក គឺជាចលករមួយបានជួយពន្លឿនដល់ទិសដៅរបស់រាជរដ្ឋាភិបាលដែលពលរដ្ឋនឹងទទួលបានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ ស្របទៅតាមយុទ្ធសាស្ត្របញ្ចកោណ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពដែលនឹងបញ្ចប់ក្នុងឆ្នាំ២០៣០ខាងមុខនេះផងដែរ ៕

**សេចក្តីថ្លែងការណ៍គាំទ្រដោយៈ**

1. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)
2. សហព័ន្ធសហជីពកម្មករចំណីអាហារនិងសេវាកម្មកម្ពុជា( CFSWF)
3. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
4. អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ - PED
5. សហពន្ធ័សហជីពឯករាជ្យ (INTUFE)
6. សហពន្ធ័សហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា(CTWUF)
7. សហជីពទ្រទ្រង់សិទ្ធិការងារ បុគ្គលិក កម្មករខ្មែរនៃលក្រុមហ៊ុនណាហ្គាវើលដ៍ (LRSU )
8. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុប បំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW )
9. សហព័ន្ធសហជីពកម្ពុជា (CATU)
10. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្ស( CENTRAL)
11. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO)
12. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
13. អង្គការតម្លាភាពកម្ពុជា (TIC)
14. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC
15. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍កម្ពុជា (ADHOC)
16. អង្គការសមាគមធាងត្នោត (STT)
17. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM)
18. សហគមន៍ព្រៃឈើ ១៨៥កាធីតាចំបក់ធំ (កំពង់ឆ្នាំង)
19. សហគមន៍ដីធ្លី ១៩៧ (កោះកុង)

20. សហគមន៍អមលាំង (កំពង់ស្ពឺ)
21. សហគមន៍បុស្សស្មោរ (ត្បូងឃ្មុំ)
22. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
23. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
24. សហគមន៍ដក់ពរ (កំពង់ស្ពឺ)
25. សហគមន៍ឃ្លាំងទឹក៧៨ (សៀមរាប)
26. សហគមន៍ជនជាតិដើមភាគតិចកួយឃុំងន (កំពង់ធំ)
27. សហគមន៍ជនជាតិដើមភាគតិចកួយ (ព្រះវិហារ)
28. សហគមន៍អូរបាត់មាន់ (ឧត្តរមានជ័យ)
29. សហគមន៍ភ្នំក្រោម (សៀមរាប)
30. សហគមន៍ពង្រកជ័យល័ក្ខ (កំពត)
31. សហគមន៍ព្រៃឈើពេជចង្វាល្អឆើត (កំពង់ឆ្នាំង)
32. សហគមន៍ដីធ្លីភូមិសិលាខ្មែរ
33. សហគមន៍ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)
34. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
35. សហគមន៍សាមគ្គីសង្កែពីរមានរិទ្ធិ (ព្រះវិហារ)
36. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
37. សហគមន៍ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ)
38. សហគមន៍ដីធ្លី ឃុំត្នោតជុំ (ពោធិ៍សាត់)
39. មជ្ឈមណ្ឌលពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព(PDP)
40. សហគមន៍បឹងប្រាំ(បាត់ដំបង)
41. សហគមន៍ដីធ្លី( ប៉ៃលិន)
42. សមាគមពង្រឹងសេដ្ឋកិច្ចក្រៅប្រព័ន្ធកម្ពុជា(CIERA)
43. សហព័ន្ធសហជីពសេរីឯករាជ្យ (FUFI)
44. សហព័ន្ធសហជីពសេរីកម្មករ នៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
45. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ(CIWA)
46. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

**ពត៍មានទំនាក់ទំនង៖**

លោក វន់ ពៅ 012 53 47 96

លោកស្រី អ៊ូ ទេពផល្លីន 011 984 883